# អាណានិគមនិយម

## គោលគំនិតសំខាន់ៗ របស់ ពួកអ្នកប្រឆាំងនឹង អាណានិគមនិយម នៅលើពិភពលោក

សរសេរ ដោយ ឧប សៅ សង្ហា




ការរីកចំរើន - អារិយធម៌ - ពាណិជ្ជកម្ម

# អាណានិគមនិយម

## មាតិការឿង

**សេចក្តីផ្តើម** .......... 3

អ្វី ដែលជា គោលការណ៍ នៃ អាណានិគមនិយម ? .......... 5

អ្វី ដែលជា លដ្ឋាភាព របស់ ប្រជាជន អាណានិគម .......... 12

កុសល ដែល លាក់បាំង អកុសល .......... 13

សេចក្តីសន្និដ្ឋាន .......... 17

សៀវភៅយោង .......... 22

# សេចក្តីផ្តើម

អារិយធម៌មួយ ដែល បង្ហាញ ថា ខ្លួន គ្មាន សម្ថភាព ដោះស្រាយ ដោយខ្លួនឯង លើ បញ្ហាទាំងឡាយ ដែល ខ្លួន ជួបប្រទះ គឺ ជា អារិយធម៌ អត្តង្គត។

អារិយាធម៌មួយ យក ជម្រើស បិទភ្នែក មិនមើល ចំពោះ បញ្ហាសំខាន់ៗទាំងឡាយ របស់ខ្លួន គឺ ជា អារិយធម៌ រងផលប៉ះពាល់ ដល់ ប្រយោជន៍ខ្លួន។

អារិយធម៌មួយ ដែលមាន ល្បិចកល ទៅលើ គោលការណ៍ របស់ខ្លួន គឺ ជា អារិយធម៌ ជិតស្លាប់។

តែ អាណានិគមនិយម នៃ មស្ចឹមប្រទេស ដែលមាន គំនិត វិនិច្ឆ័យ ទុកជាមុន ថា ខ្លួន ជា ប្រទេស មាន អារិយធម៌ ខ្ពង់ខ្ពស់ អាចនឹង ក្តាប់ និង ត្រួតត្រា លើ ប្រទេស ទន់ខ្សោយ ទាំងឡាយ នៅលើ ពិភពលោក ក្នុង អំឡុង សតវត្ស ទី ១៩-២០ តើ វាជា ទស្សនះមាន ប្រយោជន៍ សំរាប់ មនុស្សជាតិ ដែរឬទេ ? តើ ការរីកចំរើន ជាធម្មជាតិ នៃ ចិត្តគំនិត (pensée) នៃ មនុស្សលោក នៅក្នុង ការវិវត្តន៍ នៃ មនុស្សជាតិ អាចនឹង ទាំចិត្តគំនិត[1] ប្រជាជន អាណានិគម ទាំងឡាយ នៅ កំឡុងពេល នៃអាណានិគមនិយម ដែល ផ្ទុយពី ការវិវត្តន៍ នោះ ប៉ុណ្ណាទៅ ?

---

[1] ទាំងចិត្តគំនិត : កិ. ដោកជាំយូរដល់ជ្រេញចិត្ត។

# អាណានិគមនិយម

ជាការពិត បុគ្គល ម្នាក់ៗ នៃ ប្រជាជន អាណានិគម (peuple colonisé) ច្បាស់ជា រសាប់រសល់ ក្នុង អារម្មណ៍ ហើយ ចោទសួរ ដោយធុញណាយ នឹង អំពើ អាណានិគមនិយម ដែល ជា អំពើ អមនុស្សធម៌។ តើ មនុស្សព្រៃ ដែល រស់នៅ ក្នុង មជ្ឈដ្ឋានធម្មជាតិ របស់ខ្លួន អាច ពួក អាណានិគមនិយម ចាត់ទុក ជា មនុស្ស អមនុស្សធម៌ ឬ មនុស្ស យង់ឃ្នង បាន ដែរឬទេ ? តើ នៅលើ ចំណុចណាខ្លះ ដែល គេ អាច វាយ តម្លៃ ថា មនុស្សព្រៃ ជា អន្តមនុស្ស ដោយ ប្រៀបធៀប ទៅនឹង មនុស្ស បស្ចិមប្រទេស ?

គ្រប់ ចម្លើយ ដែល នឹងអាចមាន ទោះបីយ៉ាងណា ក៏គេ ពុំអាច ការពារ តម្លៃ នៃ អាណានិគមនិយម បាននោះឡើយ ព្រោះ អ្វី ដែល ធ្ងន់ធ្ងរនោះ គឺ អាណានិគមនិយម មាន លក្ខណៈ ទាំង ខាង សីលធម៌ និង គតិ ដែល គេ អាច ថ្កោលទោស បាន ដោយ គ្មាន ទេសកាល ដែល សម្រាល កំហុសបាន។ ទោសមូល[2] វា នៅក្នុង អត្ថរស់ នៃ ចិត្តគំនិត របស់ អាណានិគមនិយម តែ ម្ដង គឺ ការភូតកុហក ដោយចេតនា ដើម្បី ចម្រាញ់ យក ទ្រព្យា គ្រប់សព្វ ពី ប្រទេស អាណានិគម។ នៅក្នុង លក្ខខណ្ឌ នេះ តើ គេ អាច ប្រៀបប្រដូច អាណានិគមនិយម នឹង ការ ភូតភរ បានដែរ ឬទេ ?

[2] ទោសមូល : ន. អកុសលដែលបណ្ដាលអំពីទោស, ជាឫសនៃអកុសល។

## អាណានិគមនិយម

អពមង្គល ជាទូទៅ នៅក្នុង ការភូតភរ គឺ មាន អ្នកជឿ ដោយ សុទ្ធចិត្ត ជា ការលាក់ពុតរួម ដោយសារ តម្រង់ សំនួរ ដើម្បី ឆ្លើយ ឱ្យស្របនឹង គំនិតផ្ទាល់ ដែល ខ្លួន ចង់បានរួម ទោះបី ការដោះស្រាយ នៃ បញ្ហា វា ជា ចម្លើយ អាក្រក់ យ៉ាងណាក្ដី។ ដូច យ៉ាង ខ្មែរ ជា ទូទៅ ទុក អាណានិគមនិយម បារាំងសែស ជា ដំណោះស្រាយ អាក្រក់ តិចជាង បើ ប្រៀបធៀប ទៅនឹង ការកំរាម ពី ប្រទេស សៀម និង យួន ដែល មាន គោលបំណង បែងចែក ស្រុកខ្មែរ។ ដូច្នេះ នៅ ចំពោះមុខ អកុសល នៃ អាណានិគមនិយម អ្នករងគ្រោះ ត្រូវ មើលឃើញ ឱ្យច្បាស់, គិត ឱ្យច្បាស់ បើ ស្ដាប់ ឮអ្វី ជា គ្រោះថ្នាក់ គឺថា កុំទុកខ្លួន ជា មនុស្ស បរិសុទ្ធចិត្ត នៅក្នុង ល្បែង នៃ សំនួរ និង ចម្លើយ ដោយ នឹកស្មាន ថា នៅក្នុងនោះ វា គ្មាន ឥទ្ធិពល លាក់បាំង ឬ ស្ទួយ តម្រូវនឹង ដំណួលចិត្ត[3]។

## អ្វី ដែលជា គោលការណ៍ នៃ អាណានិគមនិយម ?

ត្រូវតែ យល់ព្រម ថា អាណានិគមនិយម មិនមែន ជា ការ ផ្សាយ សាសនា, អាជីវកម្ម សប្បុរសធម៌, ឆន្ទៈ បង្រួញ ដែន សីមា នៃ អវិជ្ជា និង ភាពខ្លៅ, ព្យាបាល រោគ របបជិះជាន់, នាំ ពង្រីក អាទិទេព ជា ច្រើន និង លាតសន្ធឹង សិទ្ធិ នៃ មនុស្ស លោក និង ប្រជាជន។ ដូច្នេះ ត្រូវតែ សារភាព ម្ដង ឱ្យហើយ ទាំងអស់ ដោយ គ្មាន មាន គោលបំណង ភាន់ច្រឡំ លើ ផល

---

[3] ដំណួលចិត្ត : ចំណុចចិត្ត។

# អាណានិគមនិយម

វិបាក ដែល បង្កើតឡើង ពី កាយវិការ ដោយ សម្រេចចិត្ត របស់ អាណានិគមនិយម ក្នុង ឋានៈខ្លួន ជា ពានេចរ និង ចោរសមុទ្រ, ជា ឈ្មួញគ្រឿងទេស ធំៗ និង នាវិកាធិបតី, ជា អ្នករកមាស់ និង អ្នកជំនួញ លក់ ទិញ ដូរ, ជា ការស្រែកឃ្លាន និងកម្លាំង ដែល នៅពីក្រោយ ស្រមោល នៃ អត្តភាព ទាំងនោះ នាំគ្នា ស្លាយ ភាពអាក្រក់ ជា រូបរាង នៃ អារិយធម៌ នៅក្នុង រយៈពេលមួយ នៃ ប្រវត្តិសាស្ត្រ របស់ខ្លួន ដោយ ដឹងថាខ្លួន មានកាតព្វកិច្ច ផ្ទាល់ខ្លួន ធ្វើ ការពង្រីក ក្នុង មាត្រដ្ឋាន ពិភពលោក នូវ ការប្រកួតប្រជែង នៃ សេដ្ឋកិច្ច បដិបក្ខ របស់ខ្លួន។ កាតព្វកិច្ច រកប្រយោជន៏នោះ នាំឱ្យខ្លួន ទុកខ្លួន ជា នាយទាហាន នៃ សណ្ដាប់ធ្នាប់ខ្ពង់ខ្ពស់ ពាក់ ឯកសណ្ឋាន ពាក់ មួកដែក កាន់ អាវុធ គ្រប់បែបយ៉ាង ដើម្បី ធ្វើ ការកាប់សម្លាប់, ប្លន់ ប្រកប ទៅដោយ ភាពលោភលន់។ ពួក អ្នកស្រែកឃ្លាននោះ ក្រោយមក បានក្លាយ ជា អ្នកទទួលខុសត្រូវ ក្នុង វិស័យរាតត្បាតនិយម នៃ សាសនាគ្រិស្ត ដោយ បានបង្កើត សមិការ (équation) មិនស្មោះត្រង់មួយ គឺ៖ សាសនាគ្រិស្ត = អារិយធម៌; ការមិនជឿសាសនា = ភាពព្រៃផ្សៃ, ដែល ជា សមិការ នាំឱ្យមាន ផលវិបាក អប្រិយ គឺ បង្កើតចេញ ជា ពួក ជនអាណានិគមនិយម និង ការប្រកាន់ ជាតិសាសន៍ ដែល មាន អ្នករងគ្រោះ គឺ ប្រជាជន តណ្ហា, ជាតិសាសន៏ សម្បុរ លឿង, ខ្មៅ នៅលើ ពិភពលោក នោះឯង។

# អាណានិគមនិយម

ជា ការពិតណាស់ហើយ បំណះ[4] អារិយធម៌ ផ្សេងៗគ្នា ជា ការល្អមួយ; សម្ពង្ស នៃ លោក ខុសគ្នា ជា ការប្រសើរបំផុត; អារិយធម៌មួយ ទោះបីមាន ទេពកោសល្យ ផ្ទាល់ខ្លួន បែបណាក៏ដោយ បើ សម្លបខ្លួន វានឹង ធ្វើឱ្យ ស្រពោន; តែ បើ មាន បំណូរ វា នឹង នាំមក នូវ ខ្យល់ សេរីសួស្ដី។ ការណ៍នេះ វាជា ការពិតមួយ, តែ អឺរ៉ុប មិនឆ្លៀត ទាញយក ផលប្រយោជន៍ ពី លាភជ័យ ដ៏ធំ របស់ខ្លួន ដែល ជា ទីប្រជុំជន និង កន្លែង ភូមិសាស្ត្រ នៃ គំនិត គ្រប់សព្វ, ជា កន្លែង ប្រជុំ ទស្សនៈវិទូ នៅលើលោក; ជា កន្លែង ស្វាគមន៍ ដល់ គតិបណ្ឌិត គ្រប់ បែបយ៉ាង ដែល នឹងអាច នាំ ឱ្យក្លាយ ជា អ្នកថែក ថាមពល ដ៏ប្រសើរ។ ការមិនឆ្លៀតនេះ វា ជា កម្មក្រាស ដល់ ពិភពលោក នៅក្នុង សតវត្ស ទី១៩។

តែ គេ អាច សួរ ជា សំនួរ ថា តើ អាណានិគមនិយម បាន ធ្វើ បំណះ រវាង អារិយធម៌ និង អារិយធម៌ ដែរឬទេ ? តាម ការពិនិត្យកត់ត្រា បញ្ជាក់ ថា ពី អាណានិគមនិយម ទៅ អារិយធម៌ វា ស្ថិត នៅ ឆ្ងាយ ពីគ្នា គ្មាន ទីបញ្ចប់; ដែល បេសកកម្ម អាណានិគមនិយម កកកុញ, ដែល គ្រប់ លក្ខន្តិកៈ នៃ អាណានិគមនិយម រៀបចំឡើង, ដែល គ្រប់ សារាចរក្រសួង គ្រប់ ប្រភេទ សំរាប់អនុវត្ត, ក៏គេ មិនអាច និយាយបាន ថា វា មិនផ្ដល់ ដាច់ខាត នូវ តម្លៃ មនុស្ស នោះដែរ។ ដូច្នេះឯង បាន ជា មាន ប្រតិនិក្ខេបបទ នៃ ការយល់ឃើញ ខាងលើ សំរាប់ ការពារ កិត្តិយស

[4] គូដែលបះគ្នា។

# អាណានិគមនិយម

នៃ អាណានិគមនិយម ថា ពិត ជា បេសកកម្ម អារិយធម៌ ដើម្បី ការរីកចំរើន នៃ មនុស្សជាតិ។

គំនិត យល់ឃើញ ថា អាណានិគមនិយម ជា បេសកកម្ម អារិយធម៌ នេះឯង ដែល នាំឱ្យ អ្នកប្រឆាំងនឹង អាណានិគមនិយម ធ្វើការសិក្សា ជា ជម្រៅ លើ របៀប បែបណា ដែល ពួកអាណានិគមនិយម បាន កំទិច អារិយធម៌ ទៅវិញទេ, ធ្វើឱ្យ អប្បយស តាម អត្ថន័យ ត្រឹមត្រូវ នៃ តម្លៃពាក្យនេះ, បន្ទត់, ដាស់ឱ្យ ភ្ញាក់ នូវ សភាវគតិ អាក្រក់ លាក់ខ្លួន នៅក្នុង ចិត្ត, ការលោភលន់, ហិង្សា, ការស្អប់ ជាតិសាសន៍, ការបន្ទូរបន្ថយ សីលធម៌ ដែល វា នាំឱ្យមាន លទ្ធការណ៍ នៃ អកុសល ដែល ថ្លឹងទម្ងន់មរណៈ របស់ខ្លួន, ការថយ នរៈតម្លៃ ជាសាកល ដែលកំពុង ប្រតិបត្ត, ដំបៅរលួយ ពាសពេញ កាយ, កន្លែង ស្អុយឡប់ ដែល រីកដាល និង នៅ ចុង នៃ សន្ធិសញ្ញា ទាំងឡាយ ដោយរំលោភ, ការភូតកុហក ផ្សេះផ្សាយ គ្រប់បែបយ៉ាង, បេសកកម្ម ជា ទណ្ឌបត្តិ គ្រប់រូបភាព ដោយ មាន ការអនុញ្ញាត, អស់ អ្នកទោស ត្រូវជាប់ ខ្នោះ និង វាយសួរចម្លើយ, អ្នកស្នេហាជាតិ គ្រប់ៗគ្នា ទទួល ទារុណកម្ម, នៅ ចុង នៃ ចិត្ត ចចើង ជាតិសាសន៍ សព្វគ្រប់ ដោយ មាន ការលើកទឹកចិត្ត, អាកប្បកិរិយា ដោយអំនួត រាលដាលនេះ, និង ការរីកសាយ បន្តិចម្តងៗ តែ ធំឡើងៗ ជានិច្ច ពិតប្រាកដ គឺ មាន គោលបំណង ធ្វើ ឱ្យ ប្រជាជន អាណនិគម ទាំងឡាយ ទៅ ជា មនុស្សព្រៃ ឬ ល្ងង់ខ្លៅ នៅចំពោះមុខ បេសកកម្ម អារិយធម៌ របស់ អាណានិគមនិយម។

# អាណានិគមនិយម

តែ នៅ ពេលមួយ ដែល ពួក អ្នកអាណានិគមនិយម ទទួល រងគ្រោះ ពី របប ណាហ្ស៊ី។ ដើមដំបូង នាំគ្នា ឆ្ងល់ ហើយ គិតស្មានថា វា នឹង ឆ្លងកាត់ ឆាប់រហូស ព្រោះ ណាហ្ស៊ីនិយម ជា របប នៃជនជាតិ ស ដូចគ្នា។ ហើយ នាំគ្នា រង់ចាំ ហើយ នាំគ្នា នៅស្ងៀមនៅ ចំពោះមុខ សច្ចះភាព នៃ ភាពយង់ឃ្នង របស់ របបនេះ។ តែ ការពិត វា ជា អំពើឃោឃៅ ខ្លាំង បំផុត ជា អំពើ បំពាក់មកុដ ដោយ ប្រជាជន អាឡឺម៉ង់ ភាគច្រើន ដែល សង្ខេប នូវអកុសល រៀងរាល់ ថ្ងៃ។ អំពើ យង់ឃ្នង បែបនេះ ប្រជាជន អឺរ៉ុបធ្លាប់ដឹងឮ និង ធ្លាប់ អត់អាស្រ័យ ដល់ ពួកជន អាណានិគមនិយម ព្រោះ មនុស្ស រងគ្រោះ វា មិនមែន ជា ជាតិសាសន៍ អឺរ៉ុប។ តែ នៅពេល ដែល ខ្លួន ជា អ្នករងគ្រោះម្តង គេ អាច សួរបាន ថា តើ នរណា ជា អ្នកទទួលខុសត្រូវ ? ពិតណាស់ហើយ គេមិនអាច ប្រៀបធៀប ទាំងស្រុង រវាង របប ណាហ្ស៊ី និង អាណានិគមនិយម ព្រោះ ណាហ្ស៊ីនិយម ប្រព្រឹត្តិ បទឧក្រិដ្ឋ មិនគ្រាន់តែ សំរាប់ រក ប្រយោជន៏ តែ ជា ឧក្រិដ្ឋកម្ម ប្រឆាំងនឹង តម្លៃនៃ ជាតិមនុស្ស។ តែ ចរិតលក្ខណ: ដូចគ្នា រវាង អាណានិគមនិយម និង ណាហ្ស៊ីនិយម គឺ ការទុកខ្លួន ជា សាសន៏ជាតិប្រសើរជាងគេ។ ទស្សនះនេះ បង្កើតចេញ ជា គំនិត មនុស្សនិយម ក្លែងក្លាយ របស់ អាណានិគមនិយម ដែល វា បន្ថួច សិទ្ធិមនុស្ស នៃ ប្រជាជន អាណានិគម ដែល ខ្លួន ទុក ជា អន្តមនុស្ស (sous-homme)។ ពិតណាស់ហើយ ថា ប្រជាជន អាណានិគម មិន ប្រាថ្នា រក សមភាព រវាង ជាតិមនុស្ស នោះឡើយ

តែ បដិសេធ នូវ ការគ្រោបសង្កត់ រវាង ជាតិសាសន៍មួយ ទៅលើ ជាតិសាសន៍ ដទៃ។ ដូច្នេះ វា មិនមែន ជា គោលបំណង លុបបំបាត់ វិសមភាព តែ ត្រូវ បង្កើត ច្បាប់ ដើម្បី បង្ក្រាប វា តែប៉ុណ្ណោះ។

តើ នរណា ដែល និយាយ សរសើរ អំពី មនុស្សនិយម និង វិជ្ជាគំនិតនិយម[5] របស់ ទស្សនវិទូ បារាំងសែស ល្បីៗ ខ្លះ ដែល យល់ឃើញ ថា «បុនភាវកម្ម[6] នៃ អន្តមនុស្សជាតិ[7] ដោយ មនុស្សខ្ពង់ខ្ពស់ គឺ ស្ថិត នៅ ក្នុង សណ្តាប់ធ្នាប់ ជា ថៃដន្យល្អ នៃមនុស្សជាតិ...។ ធម្មជាតិ បង្កើត ពូជមនុស្ស នៃ កម្មករ ដូចយ៉ាំង ពូជសាសន៍ ចិន ដែល មាន ហត្ថកោសល្យ អស្ចារ្យ តែគ្មាន អារម្មណ៍ នៃ កិត្តិយស បន្តិចទាល់តែសោះ, ដូច្នេះ បើគ្រាន់តែ ត្រួតត្រា ប្រកបដោយ យុត្តិធម៌ និង កាត់យកសម្បត្តិ មួយ ចំនួន សំរាប់ ផ្តល់ឱ្យ ពូជមនុស្សខ្ពង់ខ្ពស់ ជា អ្នកច្បាំងដណ្តើម ដែនដីបាន វា នាំឱ្យ ពូជសាសន៍នោះ មានសោមនស្ស ណាស់ទៅហើយ...។

មួយវិញទៀត នៅក្នុង សាលារដ្ឋបាល អាណានិគមនិយម នៅប្រទេស បារាំងសែស គេ អប់រំ សិស្សានុសិស្ស របស់គេ ដែល ជាអ្នកដឹកនាំ នៅពេល អនាគត នៅ ប្រទេស អាណានិគម ថា «សិទ្ធិ ចោទប្រកាន់ នៃ ការកាន់កាប់ និង សិទ្ធិ ផ្សេងៗទៀត

---

[5] វិជ្ជាគំនិតនិយម : Philosophie idéaliste.
[6] បុនភាវកម្ម : ការផ្លាស់ជាថ្មី ឬ កែជាជាថ្មី។
[7] អន្តមនុស្សជាតិ : មនុស្សជាតិទាប, race inférieure.

ដែល យល់ឃើញ ថា ការប្រគល់ សិទ្ធិ រហូត ឱ្យ ពួកជាតិសាសន៍ គ្មាន សមត្ថភាព អាច ទាញផល ពី ភាពសម្បូរណ៍ របស់ខ្លួន គឺ គ្រាន់ តែ ជា ការចោទប្រកាន់ អគតិ តែ ប៉ុណ្ណោះ...។

នៅក្នុង គោលគំនិតនេះ គេ និយាយ បាយប្រៀង[8]បញ្ឈឺចិត្ត បន្ថែម ថា « ...គឺ មនុស្សជាតិ មិនត្រូវ មាន ពិធុរ[9] ដោយសារ តែ អសមត្ថភាព, ការធ្វេសប្រហែស, កំជិល របស់ ពួក មនុស្សព្រៃ ដែល មិនចេះ ទាញផល ពី ភាពសម្បូរណ៍ របស់ខ្លួន ដែល អាទិទេព បានប្រគល់ ឱ្យខ្លួន ដើម្បី បង្កើត ផល សំរាប់ ការល្អ ដល់ ខ្លួន និង គ្រប់មនុស្សលោក ទាំងអស់គ្នា...។ ដូច្នេះ ជនអាណានិគម មិនចេះ ថែ ទ្រព្យរបស់ បណ្ដោយឱ្យ រផាត់រផុយរលីង ដែលនាំឱ្យខ្លួន រស់នៅក្នុង ភាពក្រ ដាច់ខាត។

ការសរសេរ បែបនេះ បើ បានអាន រួចហើយ គឺ ច្បាស់ ជា រឹង ខ្លួន ជា ពុំខាន។ ហើយ វា នាំ ចោទ ជា សំនួរ នៅក្នុងចិត្ត ថា ចុះដូចម្ដេច បាន ជា អ្នកប្រាជ្ញ ទាំងនោះ មាន ទស្សនៈ ទាប ថោក បែបយ៉ាងនេះ ? តែ ទស្សនៈ ទាំងឡាយនោះ វា បញ្ជាក់ ថា ប្រជាជាតិមួយ ដែល មកត្រួតត្រា លើ អារិយធម៌មួយ ហើយ រក ហេតុផល គ្រប់បែបយ៉ាង ដើម្បី សំអាង ថា អំពើ របស់ខ្លួន ជា ការត្រឹមត្រូវ គឺ ជា ប្រជាជាតិ មាន អារិយធម៌ មាន ជម្ងឺ រួចទៅហើយ, ជា អារិយធម៌ អសីលធម៌ ដោយ ពុំអាច ការពារបាន

---

8 បាយប្រៀង ៖ ពោលពាក្យបញ្ឆិតបញ្ឆៀងដៀមដាម។
9 ពិធុរ ៖ មានទុក្ខ។

# អាណានិគមនិយម

ដែលនាំ កម្មវិបាក បន្ត រហូត ហើយ ចេះតែធ្វើ ការបដិសេធ មិនចេះចប់ ថា អំពើ របស់ខ្លួន ជា អំពើ ធម្មានុរូប តាម ច្បាប់ មនុស្សជាតិ និង អាទិទេព។ តែ អំពើ ធម្មានុរូប នោះឯង ដែល នាំឱ្យ ពួក អ្នកប្រព្រឹត្ត ក្លាយ ជា តិរច្ឆាន ដោយមិនដឹងខ្លួន ទោះបីខ្លួន មានជំនឿ ថា ពួកខ្លួន ជា អារ្យជន ក៏ដោយ។

## អ្វី ដែលជា លជ្ជាភាព[10] របស់ ប្រជាជន អាណានិគម

ផុសនា[11] រវាង ពួក ជនអាណានិគមនិយម និង ប្រជាជនជន អាណានិគម គឺ ជា ការទល់មុខគ្នា រវាង ស្ទួស្វា[12] និង អ្នករង គ្រោះ។ រវាង អ្នកទាំងពីរ វា មានតែ ភារិយកម្ម[13], អភិទ្រោះ[14], សម្ពាធ, ប៉ូលីស, ពន្ធដារ, ចោរកម្ម, ការរំលោភភេទ, វប្បកិច្ច[15] ជាកាតព្វកិច្ច, អវមាន[16], ការមិនទុកចិត្ត, កន្លែងទុកខ្មោច, ចំនួនគ្រប់គ្រាន់, អំពើកម្រោល, វរជនគ្មានខួរក្បាល, ប្រជាករ នៅក្រោមឱវាទ។ គឺថា គ្មាន ផុសនា មនុស្ស និង មនុស្ស នោះ ឡើយ, មានតែ ការទាក់ទង រវាង ការគ្រោបសង្កត់ និង ការស្ដាប់បង្គាប់ ដែល ប្លែង ជនអាណានិគមនិយម ទៅជា អនុរក្ស, ព្រិន្ទបាលទោ, អ្នកយាម ពួកអ្នកជាប់ទោសឧក្រិដ្ឋ, រំពាត់

10 លជ្ជាភាព : ភាពអាម៉ាស់។
11 ផុសនា : ការប៉ះគ្នា, contact.
12 ស្ទួស្វា : អ្នកជញ្ជក់ផលប្រយោជន៍, អ្នកយកផលប្រយោជន៍។
13 ភារិយកម្ម : កំណែន, កិច្ចការលំបាកហើយគ្មានផល។
14 អភិទ្រោះ : ការសម្លុត, ការបំភ័យ។
15 វប្បកិច្ច : ការដាំ។
16 អវមាន : ការមើលងាយ។

# អាណានិគមនិយម

ហើយនិង ទុក មនុស្ស អាណានិគម ជា ឧបករណ៍ សំរាប់ បង្កើតផល។ រូបភាពទាំងឡាយនោះ គឺ ជា ភាពអាម៉ាស់ ក្រៃលែង របស់ ប្រជាជន អាណានិគម នៅក្នុង សមិការៈ អាណានិគមនិយម = ការប្លែង នៃ ទស្សនៈ ឱ្យទៅជា «របស់» (chosification)។ រូបីវត្ថុនេះ គឺ ប្លែង តម្លៃ មនុស្ស ឱ្យទៅ ឧបករណ៍ សំរាប់ ប្រើប្រាស់ ដូចជា សត្វស្រុក តួយ៉ាង គោ ក្របី ឆ្កែ ជាអាទិ៍។ ភាពអាម៉ាស់ នៃ ជនអាណានិគម ពង្រីក កាន់តែខ្លាំងឡើយ ជានិច្ច គឺ ការកន្ត្រាក់ ប្រជាជន រាប់លាននាក់ ចេញពី ជំនឿ, ភូមិ, ទម្លាប់, ជីវិតរស់នៅ, ភាសា, អក្សរ, គតិបណ្ឌិត ដើម្បី បំរើ ប្រយោជន៏ អាណានិគមនិយម ដោយ បន្ទុះគំនិត ទាំងបង្ខំ ឱ្យមាន ហីនមានៈ, ការខ្លបខ្លាច, ការភ័យញ័រ, ការលុតជង្គង់, ការអស់សង្ឃឹម, ឋានៈ ជា បាវព្រាវ ឬ កញ្ជះ។ ការបន្ទុះគំនិតនេះ គឺ ជា កម្មាជីពូនីយកម្ម នៃ ប្រជាជន អាណានិគម ក្នុងនាម នៃ បេសកកម្ម នៃ អារិយធម៌។

## កុសល ដែល លាក់បាំង អកុសល

តែ ពួក ជនអាណានិគមនិយម ពោលអះអាង ដោយ សម្លេងសំញៀង ថា អាណានិគមនិយម គឺ ការរីកចំរើន, សមិទ្ធិផល, ជម្ងឺ ជាស្រោកស្រាន្ត, ឋានៈជីវភាព ខ្ពស់ ហួសពីធ្លាប់មាន, ប្រព័ន្ធអប់រំទំនើប។ ប៉ុន្តែ កុសល ទាំងឡាយនោះ លាក់បាំង អកុសល តួយ៉ាងៈ សង្គម អាណានិគម យកចេញអត្តតម្លៃ ឲអស់ ពីខ្លួនដោយខ្លួនឯង, វប្បធម៌ ជាន់ឈ្លី, ស្ថាប័ន រីងរៃ, ដីធ្លា រឹបអូស,

## អាណានិគមនិយម

សាសនា រំខាន, លទ្ធភាព អស្ចារ្យ លុបចោល ដើម្បី កសាង សង្គមថ្មី ប្រើ ភាសាថ្មី, ស្លៀក សម្លៀកបំពាក់ បោយ[17], អនុវត្ត វប្បធម៌ថ្មី ; ដើម្បី ធ្វើ កសិកម្ម តម្រង់ទិស សំរាប់តែ សេចក្តីត្រូវការ នៃ ប្រទេស និង ប្រជាជន អាណានិគមនិយម ដែលនាំ ធ្វើឱ្យខូចខាត ដល់ កសិកម្ម ជម្មជាតិ, សុខដុម សំរាប់ ភរណកម្ម[18] របស់ ប្រជាជន អាណានិគម និង សិប្បកម្ម អាយ, ការណ៏នេះ បណ្តាល ឱ្យមាន កង្វះ ភោជន[19] និង ក្រណាត់ សំរាប់ គាត់ ធ្វើ សម្លៀកបំពាក់ នៅក្នុង មាត្រដ្ឋាន នៃ ប្រទេស ; ដើម្បី ធ្វើការហាត់រៀន វិជ្ជាជីវៈ ជា អ្នកបំរើ ជាន់ទាប នៅក្នុង រដ្ឋបាល អាណានិគមនិយម ដែល ធ្វើឱ្យ ម្ចាស់ស្រុក ភាន់ ស្មារតី ថា ខ្លួន ជា ឈ្នួល របស់ លោកធំ ជាម្ចាស់ (Monsieur Maître) ដូច បុព្វបុរស របស់ លោកធំនោះ នៅពេល ដែល គាត់ បាន ឃើញ ភាវរូប នៃ ប្រជាជន អាណានិគម លើកដំបូង គាត់ គិត ដាលវ៉ាល[20] ក្នុង ការវិនិច្ឆ័យទុកជាមុន ថា ជាតិសាសន៏នេះ គឺ កើតឡើង សំរាប់តែ ជា ធ្វើ ជា ហត្ថពលិក ឬ បាវព្រាវ របស់ អារ្យជន អឺរ៉ុប។ ហើយ ត្រូវកុំភ្លេច ថា មនុស្សទាស[21] វា គ្មាន អ្វី ប្លែក ជាង បាវព្រាវ ឬ គោ ក្របី នោះឡើយ។

---

17 បោយ : អ្នកបម្រើ។
18 ភរណកម្ម : ការចិញ្ចឹមជីវិត។
19 ភោជន : វត្ថុសំរាប់បរិភោគ, អាហារ។
20 ដាលវ៉ាល : វាលពាសពេញមិនចំពោះមុខ។
21 ទាស : ទាសៈ។

## អាណានិគមនិយម

តែ គេ សបសំដី ថា អណានិគមនិយម បង្កើត ផ្លូវ, ពេទ្យ និង សាលារៀន...។ ការណ៍នេះ វា ពិត ជា ល្បឿន នៃ ការរីកចំរើន តែ នៅពេល ឃើញ សិស្សសាលា ជា ជនអាណានិគម សម្បុរខ្មៅ ទំពា chewing-gum ពួក ជនអាណានិគមនិយម មើល ហើយ យល់ឃើញភ្លាម ថា យុវជននោះ យក ឆ្អឹងថ្គាម សំរាប់ បង្ហាញ កិរិយា ជា ជនស៊ីវិល័យ ពិតមែន តែ ដោយ ភ្លេចគិត ថា ជាតិសាសន៍ ខ្លួន មិនដែល មាន ហើយ នឹងមិនអាចមាន ជា ដាច់ខាត អ្នកប្រាជ្ញ ដូច ជាតិសាសន៍ ស តួយ៉ាង លោក Einstein ជាដើម។ គំនិត បែបនេះ វា បង្ហាញ ថា អកុសល វា មាន ជម្រៅខ្លាំងណាស់ ព្រោះ ថា អ្វី ដែល អាណានិគមនិយម បង្កើត គឺ សំរាប់ តែ ឱ្យគេ កោតសរសើរ ដល់ តម្លៃ នៃ វិសិដ្ឋភាព របស់ អារិយធម៌ អាណានិគមនិយម តែប៉ុណ្ណោះ, គ្រប់ ទម្រង់ នៃ ការធ្វើត្រាប់ ឬ ធ្វើតាម គឺ ទុក ជា ការស្រមើស្រមៃ របស់ ជនអាណានិគម ដែល វា មិន អាចនឹង កើតឡើងបាន ជា ដាច់ខាត ព្រោះ ខ្លួន ស្ថិត នៅក្នុង សាមីសម្ព័ន្ធ នៃ ពូជសាសន៍ទាប។ ការប្រដូច បែបនេះ ទុក ជា គំនិត ពភ្លីពភ្លើ ព្រោះ ជា គំនិតចម្រាញ់យកតែ សម្បុរ ស្បែក មនុស្ស មក វាយ តម្លៃ ដោយ ភ្លេចគិត ថា នៅ ស្រុកខ្មែរ មាន ប្រាង្គប្រាសាទ បុរាណ ជាច្រើន បញ្ជាក់ បង្ហាញ អំពី អត្ថភាព នៃ អ្នកប្រាជ្ញ ដែល មិនមែន ជា

សាសន៍ ស។ ដូច្នេះ គំនិត ថា ប្រជាជន អាណានិគម ជា មនុស្សព្រៃ គឺ ជា ការប្រឌិត រលោរលាំ[22] របស់ ជនជាតិ អឺរ៉ុប។

តែ ផ្លូវផ្ទាល់ បំរើ ប្រយោជន៍ អាណានិគមនិយម និង សាលារៀន មួយចំនួន បង្កើតឡើង វា មិនសម្របនឹង សេចក្តីត្រូវការ របស់ ប្រជាជន អាណានិគម នាំឱ្យមាន អតុល្យភាព នៃ សេដ្ឋកិច្ចជាតិ និង វណ្ណៈ អ្នកចេះដឹងថ្មី ឡឹតត្រេង[23] នៅក្នុង សង្គម ព្រោះ ជា ការចេះដឹង ផ្អែកទៅលើតែ ភាសា និង បច្ចេកទេស ឥតសព្វឥតសារ[24] សំរាប់ ប្រជាពលរដ្ឋ។ ប្រព័ន្ធ អប់រំ យុវជន របស់ អាណានិគមនិយម គឺ សម្លាប់ នរស្មារតី ព្រោះ បើ ខ្លួន មិនទុក ខ្លួន ជា អន្តព័ណ៌[25] នៅចំពោះមុខ លោក សាស្ត្រាចារ្យ ជាតិសាសន៍ ស គឺ ពួក លោក នឹងទុក ប្រតិកម្មនោះ ជា ឧក្រិដ្ឋកម្ម នៃ ការប្រមាថ ដល់ មនុស្សជាតិ ដ្បិត មនុស្សជាតិ ទុកដាច់ខាត អារិយធម៌ នៃ មស្ទឹមប្រទេស ជា អារិយធម៌ថ្កើង សំរាប់ ដឹកនាំ មនុស្សលោក នៅលើ លោកីយ។

លើកយក គោលគ្រឹះបី នៃ អាណានិគមនិយម ដែល ផ្អែកលើ ទ្រឹស្តី ចិត្តវិទ្យា, ភូមិសាស្ត្រវិទ្យា និង ប្រាណវិទ្យា ដែល ជា ទ្រឹស្តី ទុក ប្រទេស និង ប្រជាជន អាណានិគម ជា ដែនដី, ពាហនៈ[26] និង បាវព្រាវ ពឹងផ្អែក ទាំងស្រុក លើ ការថែទាំ របស់ អាណា

---

22 រលោរលាំ : ឈ្លានពានឥតញញើតឥតក្រែង។
23 ត្រេង : ពាក្យសំរាប់លើកគុណនាម ឱ្យមានសេចក្តីប្លែកក្រៃលែង។
24 ឥតសព្វឥតសារ : ឥតផលប្រយោជន៍ ឬ មិនបានការ។
25 អន្តព័ណ៌ : អន្តវណ្ណ, មនុស្សជាតិទាប។
26 ពាហនៈ : គ្រឿងប្រើប្រាស់សំរាប់ជិះ។

## អាណានិគមនិយម

និគមនិយម ទើបអាច រស់បាន: ប្រជាជន អាណានិគម រស់បាន ដោយសារ មាន ប្រឡៅក និង រំពាត់ផ្តៅ ទើបអាច បណ្តើរ ដើរ ទៅរក ទិសដៅ បាន។ ទ្រឹស្តី ទាំងនោះ វា ជា ការយល់ឃើញ ដោយគ្មាន ការពិចារណា ក្នុងការធ្វើ សេចក្តីសន្និដ្ឋាន ថា ប្រជាជន អាណានិគម មាន មូលមនោ[27] ជា តក្កសាស្ត្រ។ តែ តក្កសាស្ត្រ លើកមកនិយាយនេះ ជា ទ្រឹស្តី ស្ថាបនា ដើម្បី វាយតម្លៃ ដ៏ថោកបំផុត តាម ទម្លាប់ ធម្មតា ដល់ មនុស្ស អាណានិគម។

## សេចក្តីសន្និដ្ឋាន

ចិត្តគំនិត នៃ អាណានិគមនិយម ត្រូវបាន គាំទ្រ ដោយ វណ្ណៈគហបតី នៅ អឺរ៉ុប ព្រោះ វា ជា ប្រយោជន៍ ពាណិជ្ជកម្ម ចំណាយ ទន់ តិចបំផុត តែ ទាញយក ចំណេញ បានច្រើនក្រៃ។ បាវចនា នៃ អាណានិគមនិយម បារាំងសែស: ការរីកចំរើន - អារិយធម៌ - ពាណិជ្ជកម្ម វា បែងចែក ជា គោលការណ៍ បួន យ៉ាង នៅ សតវត្ស ទី ១៨ និង ទី១៩:

១. ជាលើកទី១ នៅ ពាក់កណ្តាល សតវត្ស ទី១៩ វិត្ថារកម្ម[28] ឯនាយសមុទ្រ[29] ជា ឆន្ទៈ នយោបាយ ច្បាស់លាស់ ដូចយ៉ាង ការបង្កើត អង្គការ នៃ ភូមិសាស្ត្រ មួយចំនួន, គណបក្សនយោបាយ ឈ្មោះ គណបក្ស អាណានិគមនិយម នៅ រដ្ឋសភា

---

[27] មូល: ដើម, ដើមកំណើត។ មូលមនោ: មនោដើម, mentalité primitive.
[28] វិត្ថារកម្ម: ការរាត, expansion.
[29] ឯនាយសមុទ្រ: outre-mer.

បារាំងសែស និង ការបញ្ចុះបញ្ចូល (lobby) យ៉ាងសកម្ម ។ តែការណ៍នេះ វា មិនទុក ជា អំពើចម្បង នៅឡើយទេ។

២. ព្រោះ បន្ទាប់ពី បដិវត្តន៍ បារាំងសែស និង បេសកកម្ម របស់ លោក ឧត្តមសេនីយ Bonaparte នៅ ប្រទេស អេហ្ស៊ីប ក្នុង ឆ្នាំ ១៧៩៨, វិក្តារកម្ម បារាំងសែស ធ្វើឡើង ក្នុង នាម អារិយធម៌ និង ការរីកចំរើន មិនមែន ក្នុង នាម សាសនា គ្រិស្ត ឬ ប្រយោជន៍ នៃ ពាណិជ្ជកម្ម ( ពាណិជ្ជកម្ម នៃ ទាសៈ និង ស្ករ ។ល។) នោះទេ។ នៅពេលនោះ ប្រទេស បារាំង មាន គោលបំណង បង្ហាញ ខ្លួន ថា ជា ប្រទេស ដែល ផ្តល់ឱ្យ ប្រទេស មិនទាន់ជឿនលឿន នូវ ជំនួយ នៃ ការចេះដឹង, ការអភិវឌ្ឍន៍ វិទ្យាសាស្ត្រ និង បច្ចេកទេស។ ជា ប្រទេស ដែលបាន រំដោះ ប្រជាពលរដ្ឋ ដូចយ៉ាង ប្រជាពលរដ្ឋ អេហ្ស៊ីប បន្ទាប់មក អាល់ហ្សេរី ពី ការជិះជាន់ របស់ ចក្រភព អូតូម៉ង់។ តែ ក្រោយ ពី បាន រំដោះ រួចហើយ ព្រះសង្ឃកាតូលិក មួយ ចំនួន ដែល រួមដំណើរ ជាមួយ ពួក អាណានិគមនិយម ក៏ចាប់មាន ចិត្ត ចង់ ធ្វើបរិវត្ត ប្រជាជន ប័របឺរ (Berbère) នៅ ប្រទេស អាល់ហ្សេរី ឱ្យចូល សាសនា គ្រិស្ត។

៣. អាណានិគមនិយម នៅ សត្វត្ស ទី១៩ និង ទី២០ នោះ គឺ ជា អាណានិគមនិយម នៃ « សំណង »។ ព្រោះថា នៅ ឆ្នាំ ១៨៣០ បរាជ័យ នយោបាយ ផ្ទៃក្នុង នៃ ប្រត្យាស្ថាប័ន[30] នៃ សាធារណរដ្ឋ ទី៣ ដែល មាន ទិស នយោបាយ ទៅរក នយោបាយ ចក្រព

[30] ប្រត្យាស្ថាប័ន ៖ ការស្ថាបនាឡើងវិញ។

ត្រនិយម ប្រណាំងប្រជែង ត្រូវការ ការបំភ្លេច នៃ បរាជ័យ សង្គ្រាម ជាមួយ ប្រទេស អាល្លឺម៉ង់ នៅ ដំបន់ Sedan នៅ ឆ្នាំ ១៨៧១ ដែល នាំឱ្យ បាត់បង់ ទឹកដី Alsace-Lorraine។ ដូច្នេះ សំណង គឺ នៅ ក្នុង សម្ដី របស់ លោក នាយករដ្ឋមន្ត្រី បារាំងសែស Jules Ferry ឆ្លើយ ឆ្លោះ ទៅ លោក Hansi ជាតំណាងរាស្ត្រ នៃ គណបក្ស អាណានិគមនិយម នៅក្នុង សភាជាតិ អំពី ការវាយយក ទឹកដី ឥណ្ឌូចិន និង ប្រទេស ទុយនីស៊ីថា « ខ្ញុំ បាត់ កូនពីរ (Alsace-Loraine) ពិតមែន តែ លោក បាន ផ្ដល់ សងខ្ញុំ នូវ ឈ្នួល ពីរ នាក់ វិញ »។ នៅ ដើម សតវត្សទី២០ នៅពេល ដែល ការប្រជែង បរទេស វា ខ្លាំងណាស់, ដូច្នេះ ការដណ្ដើមបាន ទឹកដី ឥណ្ឌូចិន និង ប្រទេស ទុយនីស៊ី វា អាចយកមកធ្វើ ជា សន្ទះស្នប់ (ស៊ូប៉ាប់) សំរាប់ ដោះស្រាយ ការលំបាក សេដ្ឋកិច្ច នៅពេលនោះ។

៤. អាណានិគមនិយមូបនីយកម្ម លើកទី២ មាន មធ្យោបាយ សេដ្ឋកិច្ច, ហិរញ្ញវត្ថុ, យោធា, ធនធានមនុស្ស ដែល មិនធ្លាប់មាន នៅក្នុង សតវត្ស ទី១៦ ដែល ជា ដើមទី នៃ អាណានិគមនិយម។ ជាការពិតហើយ ការបដិវត្តន៍ ឧស្សាហកម្ម វា ផ្ដល់ឱ្យ អឺរ៉ុប មាន មធ្យោបាយ ធ្វើអ្វីបាន គ្រប់បែបយ៉ាង ដែល នាំឱ្យមាន ការប្ដូរ ទាំងអស់ នូវ ការទាក់ទង រវាង មាតុធានី[31] និង ប្រទេស អាណានិគម ឬ ស្រុកចំណុះ ; ជាមួយ ប្រជាជន អាណា

[31] មាតុធានី : ពាក្យប្រៀបធៀបនឹងប្រទេសចំណុះ, métropole.

និគម ផងដែរ ដ្បិត ការងារ ដោយបង្ខំ វា ជា តម្រូវការ ដាច់ខាត ដើម្បី រួមដំណើរ ជាមួយនឹង ទំនើបកម្ម នៃ ប្រទេស អាណានិគមនិយម។

ជាការពិត ការពិភាក្សា រកខុសត្រូវ លើ អំពើ វិជ្ជមាន និង អវិជ្ជមាន របស់ អាណានិគមនិយម វា មាន ជា អនន្តរ ព្រោះ មកដល់សព្វថ្ងៃ វា នៅ មាន អតីតនគរ អាណានិគម ជា ច្រើន នៅ បន្ត រស់ ដោយ រំពឹង ជា និច្ច ទៅលើ អតីតនគរ អាណានិគមនិយម និង ប្រទេស ជឿនលឿន ស្ទើរ គ្រប់ វិស័យ។ ហើយ តម្លៃ នៃ សញ្ញាប័ត្រ នៃ ប្រទេស មហាអំណាច ធំៗ វា នៅទុក ជា វិសិដ្ឋភាព ដាច់ខាត សំរាប់ អ្នកចេះដឹង នៃ ប្រទេស ទន់ខ្សោយ ទោះបី ដឹង ថា ពុំមាន ប្រយោជន៍ ចាំបាច់ ដល់ ប្រទេស ខ្លួន ព្រោះ មិនដឹង ថា ជាតិខ្លួន ត្រូវការអ្វី ជា សារៈសំខាន់ផង។ អនិស្សរភាព[32] នៃ សេដ្ឋកិច្ច, វប្បធម៌ វា នាំ បង្កើត អាណានិគមនិយម ថ្មីមួយ នៅក្នុងនោះ មាន ការទាក់ទង រវាង ប្រទេស មហាអំណាច និង ប្រទេសក្រីក្រ ធ្វើជា រណបគេ នៅ ក្នុង សេចក្តីត្រូវការ ចាំបាច់ ដែល ជា រូបភាព ថ្មី ខុសពិត ពី អាណានិគមនិយម នៃ សតវត្ស កន្លងមក តែជា អាណានិគមនិយម ដើម្បី ផ្តល់ឱ្យ ប្រជាជន អាណានិគម គ្រាន់តែ ការរស់រានមានជីវិត (survie) និង សេដ្ឋកិច្ច រស់នៅ ជាប្រក្រតី (économie de subsistance) តែប៉ុណ្ណោះ, ហេតុតែ របប

[32] អនិស្សរភាព : ភាពនៅក្នុងចំណុះ។

# អាណានិគមនិយម

ដឹកនាំ នៃ ប្រទេសក្រីក្រ មាន អ្នកដឹកនាំ ពុករលួយ និង ខ្វះ សមត្ថភាព។

សព្វថ្ងៃ គេ ឈប់ និយាយ អំពី ការរីកចំរើន, អារិយធម៌ ខ្ពស់ ទាប, ពាណិជ្ជកម្ម ជា បេសកកម្ម នៃ អារិយធម៌ ប៉ុន្តែ គេ គិត តែ អំពី លោកូបនីយកម្ម ដែល ប្រទេសក្រីក្រ ត្រូវ ចាំបាច់ រស់ នៅ ក្នុង ផ្នត់ នៃ បទដ្ឋាន របស់ ប្រទេស មហាអំណាច សេដ្ឋកិច្ច គឺ សេចក្តីត្រូវ នៃ វត្ថុធាតុដើម, កម្លាំងពលកម្មថោក ដែល ប្រទេសទន់ខ្សោយ ជា អ្នកផ្តល់។ ការប្តូរទូទាត់ វាពិត ជា ភាពសម្បូណ៌ នៃ សេដ្ឋកិច្ច និង វប្បធម៌ សំរាប់ មនុស្សជាតិ តែ ប្រសិនបើ ធ្វើ ជា ការកេងប្រវ័ញ្ច គិត តែ រកចំណេញ គឺ ពិត ជា បង្កើត ប្រជាជន រងគ្រោះ ជា សំរាម របិុករប៉ុក បណ្តែត តៗគ្នា រពោង នៅក្នុង បន្ទាយ ទឹកស្អុយ របស់ មូលធនិក ជា បពិត្រ[33] ពិភពលោក ដែល ជា អ្នកអាណានិគមនិយមថ្មី នៅក្នុង ច្បាប់ ឥតមេត្តា របស់ លោកូបនីយកម្ម នោះឯង។ ទម្រង់ថ្មីនេះ នាំ បន្សោះ សេចក្តីសង្ឃឹម របស់ ប្រជាជន នៃ ប្រទេស ទន់ខ្សោយ ដែល រស់ ជា បម្រើ ថ្លៃថោក នៅក្នុង បាត ជា បាច់ នៃ សេដ្ឋកិច្ច ពិភពលោក។ ពិតណាស់ហើយ នៅក្នុង ការសរសេរ របស់ខ្ញុំ នេះ គឺ គ្មានបំណង អញ្ជើញ អង្គហេតុ ប្រវត្តិសាស្ត្រ នៃ អាណានិគមនិយម យកមក រំលឹក ដើម្បី ផ្តន្ទាទោស ដាច់ខាត នោះ ឡើយ។ ការរិះគន់ របស់ អ្នកប្រឆាំងនឹង អាណានិគមនិយម

[33] បពិត្រ ៈ អ្នកដែលឆ្អែតឆ្អត់ ស្កប់ស្កល់ដោយសម្បត្តិ។

# អាណានិគមនិយម

ខាងលើនេះ វា ជា និក្ខេបបទមួយ តែ វា មិនមែន មាន តម្លៃសាកល នោះដែរ។ ត្រូវដឹង ថា តាំងពីដើមឡើយ ការរុកចូល នៃ អាណានិគមនិយម ទៅក្នុង ប្រទេស ទន់ខ្សោយ ភាគច្រើន គឺ ធ្វើបានងាយស្រួល ព្រោះតែ មាន ការអនុញ្ញាតិ ពី អ្នកដឹកនាំ នៃ បណ្តា ប្រទេសទាំងនោះ ដើម្បី យកវាមក ការពារ អំណាច ឬ ប្រយោជន៍ របស់ខ្លួន តែប៉ុណ្ណោះ។ ហើយ ត្រូវដឹងទៀត ថា អ្នកដឹកនាំទាំងនោះ គាត់ មិនក្លាយ ជា ជនរងគ្រោះ នោះទេ ព្រោះ បុព្វសិទ្ធិ របស់ ពួកគាត់ ត្រូវ បាន អាជ្ញាធរ អាណានិគមនិយម គេ រក្សា ការពារឱ្យ ទាំងអស់។ អ្នកដែលរងគ្រោះពិត គឺ ប្រជាពលរដ្ឋ ឯណោះទេ។ ការរំដោះខ្លួន ចេញពី អាណានិគមនិយ ក្រោយ ពី សង្គ្រាមលោក ទី២ នៃ ប្រទេស អាណានិគម មិន មានន័យ ថា ការផ្តល់ សេរីភាព ដល់ ប្រជានុរាស្ត្រ និង ដាំ លទ្ធិប្រជាធិបតេយ្យសេរី ដែល ជា លក្ខខណ្ឌ ចាំបាច់ សំរាប់ ធ្វើ ការអភិវឌ្ឍន៍ សេដ្ឋកិច្ច, សង្គម ដើម្បី សុខុមាលភាព នៃ ប្រជាពលរដ្ឋ និង ការរីកចំរើន នៃ ប្រជាជាតិ៕

## សៀវភៅយោង


Discours sur le colonialisme : par Mr. Aimé Césaire -Edition : Présence Afrique.

Le temps des colonies : Les collections de l'HISTOIRE T 5867.